# ឈ្មោះទម្រង់អង្គុយរបស់ទេពនិករក្នុងសិល្បៈខ្មែរ

នៅក្នុងអត្ថបទមុន យើងបានរៀបរាប់ច្រើនមកហើយអំពីទម្រង់ឈររបស់ទេពនិករនៅក្នុងសិល្បៈខ្មែរ។ ដោយឡែក នៅក្នុងអត្ថបទនេះវិញ យើងនឹងរៀបរាប់បន្ថែមទៀតអំពីទម្រង់អង្គុយរបស់ទេពនិករនៅក្នុងសិល្បៈខ្មែរវិញម្តង។ តើទម្រង់អង្គុយរបស់ទេពនិករនៅក្នុងសិល្បៈខ្មែរ មានឈ្មោះហៅយ៉ាងដូចម្តេចខ្លះ? តើទម្រង់អង្គុយទាំងនេះមានឥទ្ធិពលមកពីសិល្បៈណា?

## ១. សុខសន (sukhasana)

***សុខសន*** សំដៅលើការអង្គុយមួយប្រភេទដែលដាក់ជង្គង់ខ្ពស់ត្រង់ទៅលើ ជើងឆ្វេងបត់ពបស្មើចូលក្នុង ជើងស្តាំដាក់សំយ៉ុងចុះក្រោម (មិនសំយ៉ុងត្រង់ តែជើងផាកមកចំកណ្តាល) ដែលមើលទៅហាក់ដូចជាកំពុងមានសភាពធូរស្រាល ឬពុំមានមន្ទិលអ្វីទាំងអស់។[១] ជាទូទៅ ឥរិយាបថរបៀបនេះនៅក្នុងព្រហ្មញ្ញសាសនា គេច្រើនតែឃើញឥរិយាបថរបស់ព្រះឥសូរ និងព្រះវិស្ណុ។ នៅក្នុងសិល្បៈខ្មែរ ឥរិយាបថបែបនេះគេមិនសូវនិយមធ្លាក់នៅសម័យមុនអង្គរទេ (មានតិចតួច) (រូបលេខ១) ប៉ុន្តែនៅសម័យអង្គរវិញ យើងឃើញមានភាពពេញនិយមច្រើន។ ឧទាហរណ៍ ចម្លាក់ទេព (ព្រះឥន្ទ្រ?) នៅលើផ្តែរប្រាសាទអូរផ្អុង (រូបលេខ២) ចម្លាក់ព្រះឥសូរឆ្លាក់នៅហោជាងប្រាសាទបន្ទាយស្រី (រូបលេខ៣)។

## ២. លាលីតសន (lălĭtasana)

***លាលីតសន*** សំដៅលើឥរិយាបថអង្គុយមួយប្រភេទដែលដាក់ជើងម្ខាងបញ្ឈរជង្គង់នៅលើជើងទម្រ ជើងម្ខាងទៀតដាក់ដោយសេរីដែលមើលទៅដូចធូរស្រាល ហើយជាទូទៅកាយវិការរបៀបនេះមើលទៅស្រដៀងកាយវិការមហារាជលីលាសន។[២] នៅក្នុងសិល្បៈឥណ្ឌា ឥរិយាបថនេះច្រើនតែបង្ហាញជាទេពវិនយក (ព្រះគណេស)។ ចំណែក នៅក្នុងសិល្បៈខ្មែរ ការអង្គុយរបៀបនេះមានបង្ហាញតាំងពីស.វ.ទី៧មកម្ល៉េះ ដាក់ស្តែង រូបកាល-ភៃរវ (?) នៅប្រាសាទសំបូរ តួប៉ម N1 នៃតំបន់ប្រាសាទសំបូរព្រៃគុក (រូបលេខ៤)។

## ៣. មហារាជលីលាសន (mahărāja līlăsana)

***មហារាជលីលាសន*** សំដៅលើការអង្គុយដោយដាក់ជើងស្តាំបញ្ឈរជង្គង់ ជើងឆ្វេងបត់ពបស្មើដោយម្រាមជើងឆ្វេងមកជាប់ជាមួយកែងជើងស្តាំ ដៃស្តាំដាក់លើជង្គង់ជើងស្តាំ និងដៃឆ្វេង

[១] Ganapati 2002.

[២] Pratapaditya 1986.

អត្ថបទដោយ៖ ម៉ង់ វ៉ាលី

ទម្លាក់ចុះដីឬដាក់នៅលើភ្លៅឆ្វេង។ ឥរិយាបថនេះ ជង្គង់ខ្ពស់អាចផ្អៀងបានតាមចិត្ត ខុសពីឥរិយាបថកាយវិការសុខសនដែលត្រូវដាក់ឱ្យត្រង់។ មហារាជលីលាសន ជាឥរិយាបថតំណាងឱ្យការបន្ធូរអារម្មណ៍ ឬភាពអស្ចារ្យ។[៣] នៅក្នុងសិល្បៈឥណ្ឌា ឥរិយាបថរបៀបនេះមិនត្រឹមតែមានចំពោះទេពក្នុងព្រហ្មញ្ញសាសនាប៉ុណ្ណោះទេ សូម្បីតែទេពនៅក្នុងព្រះពុទ្ធសាសនាក៏មានដែរ ឧទាហរណ៍ ព្រះពោធិសត្វ និងសិមហនាថលោកេស្វរ។ ដោយឡែក នៅក្នុងសិល្បៈខ្មែរ ការបង្ហាញឥរិយាបថមហារាជលីលាសនមានការពេញនិយមខ្លាំងតាំងពីស.វ.ទី៧មកម្ល៉េះ ជាពិសេសយើងច្រើនឃើញចម្លាក់ទេពដែលឆ្លាក់នៅលើវិមានអណ្ដែត (រូបលេខ២៥)។ នៅសម័យអង្គរវិញ កាយវិការរបៀបនេះក៏នៅតែមានភាពពេញនិយម ដូចរូបចម្លាក់តួអង្គសន្តតិវង្សបណ្ឌវ នៃរឿងមហាភារតនៅប្រាសាទបន្ទាយស្រី ជាដើម (រូបលេខ២៦)។

## ៤. **បទ្មសន** (padmasana)

**បទ្មសន** សំដៅលើការអង្គុយដោយដាក់ជើងទាំងពីររាបស្មើមកត្រួតលើគ្នា ដែលនៅក្នុងប្រពៃណីខ្មែរនិយមហៅថា "ពែនភ្នែន" ហើយ "បទ្ម" មានន័យថា "ឈូក"។[៤] ឥរិយាបថបទ្មសន គេអាចហៅម្យ៉ាងទៀតថា "**កមលសន**" ហើយបើនៅក្នុងព្រះពុទ្ធសាសនាវិញគេនិយមហៅថា "**បយ៌ង្កសន**" និង "**វជ្រសន**"។[៥] ក្នុងនោះ ប្រសិនបើជើងឆ្វេងបត់ដាក់រាបស្មើ ហើយជើងស្ដាំដាក់ប្រអប់ជើងទៅលើភ្លៅជើងឆ្វេង គេអាចហៅម្យ៉ាងទៀតថា "**អធ៌បទ្មសន**"។[៦] កាយវិការបែបនេះ នៅក្នុងសិល្បៈខ្មែរគេនិយមខ្លាំង ពោល គឺទាំងទេពនៅក្នុងព្រហ្មញ្ញសាសនា និងព្រះពុទ្ធសាសនា។ ជាក់ស្ដែង បដិមាព្រះពុទ្ធរូបអភយមុទ្រ ស.វ.ទី៦ រកឃើញនៅវត្តកំពង់ហ្លួង ស្រុកអង្គរបុរី ខេត្តតាកែវ (រូបលេខ២៧) រូបព្រះពុទ្ធសមាធិ ស.វ.ទី៦ រកឃើញនៅស្រុកគងពិសី ខេត្តកំពង់ស្ពឺ (រូបលេខ២៨) និងរូបព្រះនាងកាលិ ស.វ.ទី១០ រកឃើញនៅប្រាសាទធំ តំបន់កោះកេរ ជាដើម (រូបលេខ២៩)។

## ៥. **យោគសន** (yogasana)

**យោគ** មានន័យថា ការសមាធិដោយវិញ្ញាណឱ្យមានវិន័យ ដែលចិត្តត្រូវផ្ដោតទៅលើទេវ និងចិត្តត្រូវមានភាពរីករាយ។ ចំណែក យោគសន សំដៅលើការអង្គុយស្រដៀងឥរិយាបថបទ្មសន ពោល គឺជើងទាំងពីរដាក់បញ្ឈរជង្គង់ដោយបាតជើងទាំងពីរដាក់ខ្វែងគ្នា ហើយចងព័ទ្ធ

[៣] Ganapati 2002.

[៤] Joan & Eve 2000.

[៥] Ganapati 2002.

[៦] Ganapati 2002.

ដោយក្រណាត់មួយដែលគេហៅថា "យោគបត្ត"។[៧] ឥរិយាបថរបៀបនេះបង្ហាញអំពីការប្រៀនប្រដៅវិញ្ញាណទាំងប្រាំ ដែលជាទូទៅក្បាលត្រូវដាក់ឱ្យត្រង់ ភ្នែកសម្លឹងមើលចុងច្រមុះ ដៃទាំងពីរពេលខ្លះលើកប្រណម្យ និងខ្លះដាក់ទៅមុខ ឬដាក់លើភ្លៅក៏មាន។[៨] កាយវិការនេះ ប្រសិនបើមិនមានខ្សែក្រណាត់ព័ទ្ធជើងទាំងពីរគេអាចហៅម្យ៉ាងទៀតថា "**ស្វស្តិកសន**"។ នៅក្នុងសិល្បៈខ្មែរកាយវិការរបៀបនេះ ច្រើនបង្ហាញជារូបឥសី ដែលយើងឃើញដំបូងគេនៅសំបូរព្រៃគុក ស.វ.ទី៧ ឆ្លាក់នៅវិមានអណ្តែត (រូបលេខ១០) ហើយនៅសម័យអង្គរវិញ គេនិយមឆ្លាក់តាមជើងសសរពេជ្រ (រូបលេខ១១) និងខ្លះទៀតឆ្លាក់ជាបដិមាទោលក៏មាន (រូបលេខ១២)។

ក្រៅពីទម្រង់អង្គុយខាងលើ នៅមានទម្រង់ជាច្រើនទៀត ដែលមិនសូវនិយមឆ្លាក់នៅក្នុងសិល្បៈខ្មែរ ដូចជា គរុឌសន (garuḍasana) រាជលិង្គសន (răjaliṅgasana) វិរសន (virasana) ឧត្កុតិកសន (utkutikasana)[៩]។ល។

ជារួមមក ទម្រង់អង្គុយរបស់ទេពនៅក្នុងសិល្បៈខ្មែរមានលក្ខណៈសម្បូណ៌បែបណាស់ ហើយទម្រង់ទាំងនោះ ស្ទើរតែទាំងអស់ខ្មែរបានទទួលឥទ្ធិពលពីសិល្បៈឥណ្ឌា។ ទម្រង់អង្គុយនីមួយៗ សុទ្ធសឹងមានអត្ថន័យនិងផ្ទត់គំនិតខាងក្នុង។ យ៉ាងណាក៏ដោយ ឥរិយាបថនៃការអង្គុយរបស់ទេពដែលបានបង្ហាញខាងលើ គ្រាន់តែជាការបង្ហាញទម្រង់ខ្លះៗប៉ុណ្ណោះ។

## ឯកសារយោង

**Ganapati, Sthapati, V.**
2002, *Indian sculpture & iconography, forms and measurements,* Sri Aurobindo Institute of Research in Social Sciences, India.

**Heinrich Robert, Z.**
2015, *Myths and symbols in Indian art and civilization*, Pinceton University Press.

**Joan, B. & Eve, A.**
2000, *The complete idoit's guide to yoga*, Penguin.

**Pratapaditya, P.**
1986, 'Indian sculpture: Circa 500 B.C. to A.D. 700'*, Indian sculpture: A catalogue of the Los Angeles county museum of art collection,* Volume I, Los Angeles county museum of art/university of California Press.

[៧] Heirich Robert 2015.

[៨] Ganapati 2002.

[៩] Ganapati 2002.

អត្ថបទដោយ៖ ម៉ង់ រ៉ាលី



រូបលេខ១៖ ចម្លាក់ទេពអង្គុយក្នុងទម្រង់សុខសន នៅសំបូរព្រៃគុក N11 ស.វ.ទី៧



រូបលេខ២៖ ចម្លាក់ទេពអង្គុយក្នុងទម្រង់សុខសន នៅប្រាសាទអូរផ្អុង ស.វ.ទី៩



រូបលេខ៣៖ ចម្លាក់ព្រះឥសូរអង្គុយក្នុងទម្រង់សុខសន នៅប្រាសាទបន្ទាយស្រី ស.វ.ទី១០ (រូបថត៖ គុំ រតនៈពិសិដ្ឋ)

អត្ថបទដោយ៖ ម៉ង់ វ៉ាលី



រូបលេខ២៤៖ ចម្លាក់ទេពកាលៈកែវរអង្គុយក្នុងទម្រង់លាលីតសន នៅសំបូរព្រៃគុក N1 ស.វ.ទី៧ (រូបថត៖ កុំ រតនៈពិសិដ្ឋ)



រូបលេខ២៥៖ ចម្លាក់ទេពកាលៈកែវរអង្គុយក្នុងទម្រង់មហារាជលីលាសន នៅប្រាសាទជ្រូកគាស់ (សំបូរព្រៃគុក) ស.វ.ទី៧

អត្ថបទដោយ៖ ម៉ង់ វ៉ាលី



រូបលេខ២៦៖ ចម្លាក់តួអង្គសន្តតិវង្សបណ្ឌវអង្គុយក្នុងទម្រង់មហារាជលីលាសន នៅប្រាសាទបន្ទាយស្រី ស.វ.ទី១០



រូបលេខ២៧៖ បដិមាព្រះពុទ្ធអភយមុទ្រអង្គុយទម្រង់បទ្មសន រកឃើញនៅវត្តកំពង់ហ្លួង ខេត្តតាកែវ ស.វ.ទី៦



រូបលេខ២៨៖ បដិមាព្រះពុទ្ធសមាធិអង្គុយទម្រង់បទ្មសន រកឃើញនៅស្រុកគងពិសី ខេត្តកំពង់ស្ពឺ ស.វ.ទី៦

អត្ថបទដោយ៖ ម៉ង់ វ៉ាលី



រូបលេខ៩៖ បដិមាព្រះនាងកាលិអង្គុយទម្រង់បទ្មសន នៅប្រាសាទធំ កោះកេរ ស.វ.ទី១០



រូបលេខ១០៖ ចម្លាក់ឥសីអង្គុយទម្រង់យោគសន នៅសំបូរព្រៃគុក N11 ស.វ.ទី៧ (រូបថត៖ ឯម ភារក្ស)



រូបលេខ១១៖ ចម្លាក់ឥសីអង្គុយទម្រង់យោគសន នៅជើងសសរពេជ្រប្រាសាទបន្ទាយសំរ៉ែ ស.វ.ទី១២



រូបលេខ១២៖ បដិមាឥសីអង្គុយទម្រង់យោគសន នៅប្រាសាទព្រះគោ ស.វ.ទី៩

អត្ថបទដោយ៖ ម៉ង់ វ៉ាលី